# ថ្ងៃបូជា

## អារម្ភកថា

សៀវភៅមានឈ្មោះថា **ថ្ងៃបូជា** នេះ ខ្ញុំសរសេរឡើង ដោយមានបំណងចង់ឲ្យពុទ្ធបរិស័ទទូទៅបានយល់ដឹងអំពីមូលហេតុនៃថ្ងៃបូជាទាំង ៣ មានអសាឡ្ហៈបូជាជាដើមបានដោយងាយ ជាពិសេស ថ្ងៃអសាឡ្ហៈបូជាដែលកន្លងមកយើងពុំបានដឹង ពុំសូវនាំគ្នាប្រារព្ធធ្វើឡើយ ។

ខ្ញុំសង្ឃឹមថា បើលោកអ្នកបានអាននូវសៀវភៅនេះ ពិតជាមានការយល់ដឹងនូវថ្ងៃបូជាដ៏សំខាន់ៗទាំង ៣ នេះហើយនឹងបង្អោនចិត្តទៅដោយការបូជានៅក្នុងថ្ងៃនិមួយៗពុំខានឡើយ ។

**គិរីរម្យ**

ព.ស. ២៥៤៧

ថ្ងៃ ៦ រោច ខែ មាឃ : ---------

គ.ស. ២០០៤

ភិក្ខុ សុន្ទ៍ សាមៀន

Document Produced by deskPDF Unregistered :: http://www.docudesk.com

**សួរ,** តើថ្ងៃណាខ្លះ ដែលជាថ្ងៃបូជាសំខាន់ៗជាងគេក្នុងព្រះពុទ្ធសាសនា ?
**ឆ្លើយ,** ថ្ងៃបូជាដែលសំខាន់ៗជាងគេនៅក្នុងព្រះពុទ្ធសាសនាមាន ៣ គឺៈ

ថ្ងៃ ១៥ កើត ខែ អាសាឍ
ថ្ងៃ ១៥ កើត ខែ មាឃ
ថ្ងៃ ១៥ កើត ខែ ពិសាខ ។

**សួរ,** ចូររៀបរាប់អំពីសារៈសំខាន់ៗនៃថ្ងៃបូជាទាំង ៣ នេះមកមើល ?
**ឆ្លើយ,** ថ្ងៃបូជាទាំង ៣ នេះសុទ្ធតែមានសារៈសំខាន់ៗដូចតទៅៈ

**១, ថ្ងៃ ១៥ កើត ខែ អាសាឍ** មានចំណុចសំខាន់ៗ **៥** យ៉ាង ដែលយើងត្រូវធ្វើការបូជា គឺៈ

**ជា**ថ្ងៃដែលព្រះអង្គយាងចុះចាប់បដិសន្ធិ ។
**ជា**ថ្ងៃដែលព្រះអង្គទ្រង់យាងចេញសាងព្រះផ្នួស ។
**ជា**ថ្ងៃដែលព្រះអង្គសំដែងព្រះធម្មទេសនា ។
**ជា**ថ្ងៃដែលព្រះអង្គស្ថាបនាឲ្យមានព្រះភិក្ខុសង្ឃ ។
**ជា**ថ្ងៃដែលព្រះអង្គទ្រង់សំដែង យមកប្បាដិហារ្យ ។

**២, ថ្ងៃ ១៥ កើត ខែ មាឃ** មានចំណុចសំខាន់ៗ **៥** យ៉ាងដែល យើងត្រូវធ្វើការបូជា គឺៈ

Document Produced by deskPDF Unregistered :: http://www.docudesk.com

ជាថ្ងៃ មាឃនក្ខត្តឫក្ស គឺព្រះចន្ទភ្លឺច្បាស់ល្អ ។
ជាថ្ងៃភិក្ខុសង្ឃជំនួន ១ ២៥០អង្គមកជួបជុំគ្នាដោយឥតបានណាត់ទុក ។ ភិក្ខុសង្ឃទាំងឡាយនេះសុទ្ធតែជាព្រះអរហន្តទីណាស្រេពបួសជាឯហិភិក្ខុ ។
ជាថ្ងៃដែលព្រះពុទ្ធគ្រប់ៗអង្គទ្រង់សំដែងនូវឱវាទបាដិមោក្ខនិងដាក់ព្រះជន្មាយុសង្ខារ ។
ជាថ្ងៃដែលព្រះសារីបុត្រ អគ្គសាវកស្តាំបានសម្រេចធម៌ជាន់ខ្ពស់ ។
ជាថ្ងៃដែលព្រះទ្រង់ស្ថាបនាអគ្គសាវកទាំង ២ ។

**៣, ថ្ងៃ ១៥ កើត ខែ ពិសាខ** មានចំណុចសំខាន់ **៧** យ៉ាងដែលយើងត្រូវធ្វើការគោរពបូជា គឺ:

ជាថ្ងៃដែលព្រះអង្គ បានទទួលការព្យាករណ៍ថា នឹងបានត្រាស់ដឹងជាព្រះពុទ្ធក្នុងពេលដែលព្រះអង្គនៅជាព្រះពោធិសត្វ ( សុមេធបណ្ឌិត ) ។
ជាថ្ងៃដែលព្រះអង្គ ទ្រង់ប្រសូតិ ។
ជាថ្ងៃដែលព្រះពោធិព្រឹក្សដុះឡើង ។
ជាថ្ងៃត្រាស់ដឹងរបស់ព្រះពុទ្ធ ។
ជាថ្ងៃដែលព្រះអង្គ ទ្រង់សំដែងនូវឱវាទចុងក្រោយបង្អស់ ។
ជាថ្ងៃដែលព្រះអង្គ ទ្រង់យាងចូលកាន់បរិនិព្វាន ។
ជាថ្ងៃដែលធាតុបរិនិព្វាន ( នឹងមានក្នុងអនាគត ) ។

ពុទ្ធបរិស័ទ កាលបើបានដល់ថ្ងៃបូជាទាំង ៣ នេះហើយ គួរធ្វើកុសល ៣

Document Produced by deskPDF Unregistered :: http://www.docudesk.com

ប្រការ គឺ **ការឲ្យទាន** **រក្សាសិល** និង **ចំរើនភាវនា** ឲ្យពិសេសជាងប្រក្រតី ព្រោះថា កុសល ៣ ប្រការនេះ ជាការបតិបត្តិតាម **លោកុត្តរធម៌** ។

កាលបើបានឲ្យទាន រក្សាសិល ចំរើនភាវនាហើយ ក៏គួរបូជាព្រះរតនត្រៃដោយបញ្ចេញវាចាថា:

**ឥមាយ ធម្មានុធម្មប្បតិបត្តិយា ពុទ្ធំ បូជេមិ**
**ឥមាយ ធម្មានុធម្មប្បដិបត្តិយា ធម្មំ បូជេមិ**
**ឥមាយ ធម្មានុធម្មប្បដិបត្តិយា សង្ឃំ បូជេមិ**

ព្រះពុទ្ធ
ខ្ញុំសូមបូជានូវ ព្រះធម៌ ដោយការបដិបត្តិនូវធម៌ដ៏សមគួរដល់ធម៌
ព្រះសង្ឃ
( លោកុត្តរធម៌ )នេះ ។

បន្ទាប់មកគួរបញ្ចេញវាចាថា:

**អទ្ធា ឥមាយ បដិបត្តិយា ជរាមរណម្ហា បរិមុច្ចិស្សាមិ**

ខ្ញុំនឹងរួចផុតចាកជរានិង មរណៈ ដោយការបដិបត្តិយ៉ាងនេះជាពិតប្រាកដ ។

**គិរីរម្យ**
ព.ស. ២៥៤៧
ថ្ងៃ ៦ រោច ខែ មាឃ : -----------
គ.ស. ២០០៤

ភិក្ខុ សុន្ទរ៍ សាមៀន

Document Produced by deskPDF Unregistered :: http://www.docudesk.com